00275510

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C22/5/10

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៧)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៍យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ២៩ មករា ២០០៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 01 / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Tuy

---

សាធារណៈ:

សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើ មូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ និងដីកាកំណត់កាលបរិច្ឆេទសវនាការ

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke STUDZINSKY
យុង ផានិត
គឹម ម៉េងឃី
Martine JACQUIN
ម៉ុច សុវណ្ណារី
Philippe CANNONE
Pierre Olivier SUR

**សហមេធាវីការពារក្តី**

អាង ឧត្តម
Michael G. KARNAVAS

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 29 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Tuy

00275511



១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") កត់សម្គាល់ឃើញមាន "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ **អៀង សារី** ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន" ("ចម្លើយតប")។ ចម្លើយតបនេះ បានដាក់នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩ ដែលនៅក្នុងនោះ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គបុរេជំនុំជម្រះ សម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ("សំណើ")។

២. នៅក្នុងសំណើរបស់ខ្លួន, សហព្រះរាជអាជ្ញាសន្និដ្ឋានថា "នៅពេលដែលសហព្រះរាជអាជ្ញា គាំទ្រឱ្យមានសវនាការផ្ទាល់មាត់មួយលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួននេះ បណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះទាក់ទងតែទៅនឹងការបន្តថិរវេលាដែលត្រូវបានបញ្ជាក់អះអាងថាត្រឹមត្រូវក្នុងពេលថ្មីៗនេះតែប៉ុណ្ណោះ ហើយដូចនេះ មិនមានលើកឡើងនូវទឡ្ហីករណ៍ខាងអង្គហេតុនិងអង្គច្បាប់ណាថ្មីទៀត ដែលចាំបាច់ត្រូវលើកឡើងនៅក្នុងសវនាការផ្ទាល់មាត់មួយនោះទេ។"[១]

៣. នៅក្នុងសេចក្តីបង្គាប់ចេញថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានអញ្ជើញឱ្យភាគីនានា ដែលពាក់ព័ន្ធនៅក្នុងរឿងក្តីនេះ ដាក់សេចក្តីសន្និដ្ឋានតប ត្រឹមថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩។

៤. នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩, សហមេធាវីការពារក្តីបានដាក់ "ចម្លើយតបរបស់លោក **អៀង សារី** ចំពោះសេចក្តីបង្គាប់របស់អង្គជំនុំជម្រះចំពោះសំណើរបស់សហព្រះរាជអាជ្ញាដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។" នៅក្នុងចម្លើយតបនោះ សហមេធាវីការពារក្តី ស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលសំណើរបស់សហព្រះរាជអាជ្ញា ហើយធ្វើការកំណត់កាលបរិច្ឆេទសវនាការពេញដោយ។ សហមេធាវីការពារក្តីសន្និដ្ឋានថា ការសន្មតជាមុនគឺផ្តល់ប្រយោជន៍ឱ្យមានសវនាការពេញដោយផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ហើយ"បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចបន្តការឃុំខ្លួនលោក **អៀង សារី** រយៈពេលមួយឆ្នាំបន្ថែមទៀតនោះ គឺមានសារៈសំខាន់ខ្លាំងណាស់។" សហមេធាវីការពារក្តីទាមទារឱ្យមានសវនាការមួយរៀបចំឡើង ដើម្បីអនុញ្ញាតឱ្យសហមេធាវីការពារក្តី (១) លើកបញ្ហាសុខភាពដ៏រុំារ៉ៃរបស់ជនត្រូវចោទ ដែលតម្រូវឱ្យបញ្ជូនចូលមន្ទីរពេទ្យ ចាប់តាំងពីពេលដាក់សារណាបណ្តឹងឧទ្ធរណ៍ និង (២) ឆ្លើយតបជាសាធារណៈ ចំពោះទឡ្ហីករណ៍នានា ដែលដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងរួមគ្នានៅក្នុងចម្លើយតប

[១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ **អៀង សារី** ប្រឆាំងនឹងការបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩ C22/5/7 វាក្យខណ្ឌទី ៣។

00275512



C22/5/10

ចំពោះបណ្ដឹងឧទ្ធរណ៍ "អំពីការគម្រាមកំហែងចំពោះសណ្ដាប់ធ្នាប់សាធារណៈ បង្កឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនឯង។"[២]

៥. វិធាន ៧៧ នៃវិធានផ្ទៃក្នុង (វិ.២) វិសោធនកម្មនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ចែងនៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធថា:

> "៣. (ខ) បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្ដឹងឧទ្ធរណ៍ ឬពាក្យសុំ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។"

៦. ដោយទទួលស្គាល់អំពីសារៈសំខាន់នៃបណ្ដឹងឧទ្ធរណ៍ ដែលពាក់ព័ន្ធនឹងសេរីភាពរបស់ជនត្រូវចោទ និងដោយពិចារណាថា សហមេធាវីការពារក្ដី បានស្នើសុំឱ្យមានសវនាការដេញដោល, អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសមស្របក្នុងការរៀបចំសវនាការនេះឡើង មុនពេលសម្រេចលើបណ្ដឹងឧទ្ធរណ៍។

៧. ជាគោលការណ៍ចំបង សវនាការលើរឿងក្ដីនេះ ត្រូវធ្វើឡើងជាសាធារណៈ។

## ហេតុដូច្នេះអង្គបុរេជំនុំជម្រះ÷

(១) **បដិសេធចោល**សំណើសុំឱ្យធ្វើការសម្រេចលើបណ្ដឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរណ៍តែប៉ុណ្ណោះ។

(២) **កំណត់**បើកសវនាការនៅថ្ងៃទី**២៦ ខែកុម្ភៈ ឆ្នាំ២០០៨** វេលាម៉ោង **៩:០០ ព្រឹក**។ និង

(៣) **អញ្ជើញ**គ្រប់ភាគីដែលពាក់ព័ន្ធនឹងរឿងក្ដីនេះ ចូលរួមនៅក្នុងសវនាការតាមកាលបរិច្ឆេទកំណត់។

ភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

**ប្រាក់ គឹមសាន**

[២] ចម្លើយតបរបស់លោក **អៀង សារី** ចំពោះសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះចំពោះសំណើរបស់សហព្រះរាជអាជ្ញាដើម្បីកំណត់លើបណ្ដឹងឧទ្ធរណ៍ ដោយផ្អែកមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ C22/5/9 វាក្យខណ្ឌទី ១, វាក្យខណ្ឌទី ៦, និង វាក្យខណ្ឌទី ១០។